# កម្មវិធីសន្ទនាតាមវិទ្យុ

## “ស្វែងយល់ពីច្បាប់សំខាន់ៗដែលជាឧបករណ៍លើកកំពស់ អភិបាលកិច្ចល្អ”

*សម្រាប់ថ្ងៃច័ន្ទ ទី ២៨ ខែ មីនា ឆ្នាំ ២០១១*

**ចំនួនអត្ថបទ៖** ៣៥០ *ដំណឹងសំខាន់ៗប្រចាំសប្តាហ៍៖ ៤ដំណឹង*

### ១. *ប្រជាពលរដ្ឋភូមិបឹងព្រៃកទប់ គ្រោងរកអន្តរាគមន៍ពីសម្តេចតេជោ ហ៊ុន សែន*

យ៉ាងហោចណាស់ក៏មានកាសែតក្នុងស្រុកចំនួនបីដែរ គឺកាសែត ***រស្មីកម្ពុជា កម្ពុជាថ្មី*** និង ***នគរវត្ត*** បានចុះផ្សាយយ៉ាងតិច ២ លេខ នូវព័ត៌មានទាក់ទងនឹងការចោទប្រកាន់មន្ត្រីខេត្តព្រះសីហនុ ពាក់ព័ន្ធទៅនឹងការចេញប័ណ្ណកម្មសិទ្ធិលំនៅដ្ឋាន ដល់ប្រជាពលរដ្ឋ។ ***រស្មីកម្ពុជា*** ចេញផ្សាយថ្ងៃទី២៣ មីនា បានសរសេរថា ប្រជាពលរដ្ឋរស់នៅជុំវិញបឹងព្រៃកទប់ ដែលជាប្រភពទឹកស្អាតក្នុងខេត្តព្រះសីហនុ មានគំរោងរកអន្តរាគមន៍ពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន លើករណីឆបោក ក្រោមរូបភាពសន្យាថានឹងចេញប័ណ្ណកម្មសិទ្ធិស្របច្បាប់ដល់ប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ។ ប្រតិកម្មខាងលើនេះ បានកើតឡើងបន្ទាប់ពីប្រជាពលរដ្ឋដឹងថា ខ្លួនបានចាញ់បោកអ្នកធានាក្នុងការរត់ការចេញប្លង់កម្មសិទ្ធិលើដីលំនៅដ្ឋាន ដែលបានមករស់នៅតាំងពីឆ្នាំ១៩៧៩មក។ ពលរដ្ឋម្នាក់រស់នៅតំបន់ព្រៃកទប់នេះបានប្រាប់ ***រស្មីកម្ពុជា*** ថា ដោយហេតុតែចង់រស់នៅស្របច្បាប់ ពួកគាត់បានចាញ់បោកក្រុមធានារត់ការយ៉ាងធ្ងន់ធ្ងរ ដោយត្រូវអ្នកទាំងនោះប្រមូលយកប្រាក់ពីពួកគាត់អស់ច្រើនសន្ធឹកសន្ធាប់ ប៉ុន្តែមិនបានរត់ការចេញប្លង់កម្មសិទ្ធិឱ្យពួកគាត់តាមការសន្យាឡើយ។ ដោយឡែក កាសែត ***នគរវត្ត*** ចេញផ្សាយថ្ងៃទី២២ មីនា បានឱ្យដឹងថា អ្នកទទួលរងការចោទប្រកាន់ពីប្រជាពលរដ្ឋនោះ បានឆបោកយកលុយចំនួន៣០ម៉ឺនដុល្លារ ដើម្បីរត់ការចេញប័ណ្ណកម្មសិទ្ធិនោះ...និងថាគិតចាប់ពីពេលដែលក្រុមអ្នកធានាបានប្រមូលលុយពីប្រជាពលរដ្ឋរហូតមកដល់ពេលនេះ គឺមានរយៈពេលពីរឆ្នាំ ហើយក្រុមប្រជាពលរដ្ឋក៏មិនបានទទួលប្លង់កម្មសិទ្ធិស្របច្បាប់អ្វីនោះដែរ។ ផ្ទុយទៅវិញ ពួកគាត់បែរជាបានទទួលដំណឹងថាមាន ស.ជ.ណ មួយ ដើម្បីអភិវឌ្ឍន៍តំបន់នោះជាតំបន់ទេសចរណ៍។ ទោះជាយ៉ាងណាក៏ដោយ ***នគរវត្ត*** បានឱ្យដឹងថាមន្ត្រីជំនាញខាងសុរិយោដីខេត្តព្រះសីហនុ បានបញ្ជាក់ថាដីនៅតំបន់បឹងព្រៃកទប់ គឺមិនអាចចេញប្លង់កម្មសិទ្ធិជាលក្ខណៈប្រព័ន្ធបានទេ ព្រោះពាក់ព័ន្ធនឹងអចលនទ្រព្យរបស់រដ្ឋ ហើយចំពោះការសាងសង់ប្លង់ជាប្រព័ន្ធកន្លងមក ក៏គ្មានការទទួលប្រាក់កម្រៃស៊ីសំណូកសូកប៉ាន់អ្វីដែរ។

### ២. *មន្ត្រីប៉ូលិសស្រុកសំឡូតរំជើបរំជួលបន្ទាប់ពីត្រូវអធិការស្រុកកាត់ប្រាក់ខែ*

កាសែត***កម្ពុជាថ្មី*** ចេញផ្សាយថ្ងៃទី ២៣ មីនា បានឱ្យដឹងថា កំលាំងនគរបាលស្រុកសំឡូតទាំងអស់កំពុងតែមានប្រតិកម្មយ៉ាងខ្លាំង ដោយសារតែរយៈពេលជិត១ឆ្នាំកន្លងទៅ មានការលួចកាត់ប្រាក់បៀវត្សរ៍ប្រចាំខែដោយមិនដឹងពីមូលហេតុ និងថាមានមន្ត្រីប៉ូលិសជាច្រើនរូបបានត្អូញត្អែរថា ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១០មក ការបើកប្រាក់ប្រចាំខែរបស់ពួកគាត់ ត្រូវបាន

អធិការនគរបាលស្រុកសំឡូតបញ្ជាឱ្យអ្នកកាន់បញ្ជីបើកប្រាក់ខែ កាត់យក ដោយក្នុងមន្ត្រីប៉ូលិសមួយរូបចាប់ពី១៥០០០ ទៅ ២៥០០០រៀល រៀងរាល់ខែ។ ប្រភពបានបន្តថាការកាត់ប្រាក់ខែរបស់មន្ត្រីប៉ូលិសក្នុងស្រុកសំឡូតនេះ គឺមិនមានការប្រជុំពិភាក្សាថាជាការកាត់ដោយយោងទៅលើមូលហេតុអ្វីឡើយ។ មន្ត្រីប៉ូលិសសុំមិនបញ្ចេញឈ្មោះមួយរូប បានឱ្យដឹងថាមានការប្រព្រឹត្តអំពើពុករលួយជាច្រើនទៀត ពីសំណាក់អធិការនគរបាលស្រុកសំឡូត ដូចជាការប្រកាសដំឡើងស័ក្តិមន្ត្រីនគរបាល ក៏ត្រូវលោកអធិការទារលុយផងដែរ។ ជាក់ស្តែងរូបលោកផ្ទាល់តែម្តង ដោយគ្រាន់តែរូបលោកត្រូវថ្នាក់លើប្រកាសប្តូរពីស័ក្តិ ២ឡើងទៅស័ក្តិ៣ ក៏ត្រូវលោកអធិការទារលុយអស់ជិតម្ភៃម៉ឺនរៀល ហើយលោកត្រូវបានគេកាត់ប្រាក់បៀវត្សរ៍ប្រចាំខែអស់ ២៥០០០ រៀល ជាប្រចាំ។ លោកបានសំណូមពរដល់អគ្គនាយកដ្ឋាននគរបាលជាតិ និងអង្គភាពប្រឆាំងអំពើពុករលួយ ឱ្យចុះត្រួតពិនិត្យស៊ើបអង្កេតលើករណីកាត់ប្រាក់បៀវត្សរ៍ ក៏ដូចជាប្រភពនៃទ្រព្យសម្បត្តិរបស់លោកអធិការស្រុកសំឡូត ផងដែរ។

### ៣. *មន្ត្រីទូតកម្ពុជាប្រចាំនៅសាធារណៈរដ្ឋកូរ៉េ រងការចោទប្រកាន់ថាជំរិតថ្លៃធ្វើលិខិតបញ្ជាក់ និងពន្យារលិខិតឆ្លងដែន*

ការចោទប្រកាន់មួយលើមន្ត្រីស្ថានទូតកម្ពុជាប្រចាំនៅសាធារណៈរដ្ឋកូរ៉េ ត្រូវបានចុះផ្សាយដោយកាសែត ***ភ្នំពេញប៉ុស្តិ៍*** ថ្ងៃទី ២៥ មីនា បន្ទាប់ពីកាសែតនេះបានទទួលសារអេឡិចត្រូនិកមួយពីក្រុមពលករខ្មែរបំរើការងារនៅសាធារណៈរដ្ឋកូរ៉េ។ កាសែតនេះបានសរសេរថាពលករខ្មែរបម្រើការងារតាមសហគ្រាស ក្រុមហ៊ុន នៅទីនោះ បានស្នើរដ្ឋាភិបាលធ្វើការត្រួតពិនិត្យមើលពីបញ្ហាមន្ត្រីស្ថានទូត ជំរិតទារប្រាក់ពីពលករច្រើនហួស លើថ្លៃពន្យារលិខិតឆ្លងដែន និងការបញ្ជាក់លិខិតមួយចំនួន មានតំលៃពី ២០០ដល់៩០០ដុល្លារ។ ***ភ្នំពេញប៉ុស្តិ៍*** ក៏បានទទួលផងដែរនូវការបញ្ជាក់បន្ថែមពីពលករខ្មែរតាមរយៈទូរស័ព្ទ ដោយលើកឡើងពីករណីជាក់ស្តែងក្នុងការជំរិតទារប្រាក់ និងថាមានពលករចំនួន១០០នាក់បានរួមគ្នាសរសេរលិខិតជម្រាបពីទង្វើរបស់ក្រុមមន្ត្រីស្ថានទូតខ្មែរដើម្បីចុះផ្សាយនិងសំណូមពរឱ្យមានអន្តរាគមន៍ពីរាជរដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ ***ភ្នំពេញប៉ុស្តិ៍*** បានដកស្រង់ប្រសាសន៍ឯកឧត្តម កុយ គួង មន្ត្រីនាំពាក្យក្រសួងការបរទេស ថាការពន្យារលិខិតឆ្លងដែន ឬធ្វើលិខិតបញ្ជាក់ផ្សេងៗ គឺមិនតម្រូវឱ្យមន្ត្រីស្ថានទូតយកប្រាក់ពីពលរដ្ឋកម្ពុជាឡើយ តែបើករណីនេះកើតមានមែន គឺមានតែយកទៅដាក់ក្នុងហោប៉ៅផ្ទាល់ខ្លួន។ ម្យ៉ាងវិញទៀត លោកកំពុងតែទាក់ទងទៅមន្ត្រីស្ថានទូតនៅសាធារណៈរដ្ឋកូរ៉េ ដើម្បីឱ្យឆ្លើយតបចំពោះការចោទប្រកាន់នេះ។

### ៤. *មិនទាន់មានវិធានការចំពោះការលួចកែទិន្នន័យនិស្សិតអាហារូបករណ៍ របស់នាយកដ្ឋានឧត្តមសិក្សា*

គួររំឭកថាប៉ុន្មានថ្ងៃកន្លងមកនេះ មានការចុះផ្សាយជាច្រើននៅលើទំព័រសារពតិមាន ជុំវិញភាពមិនប្រក្រតីក្នុងការជ្រើសរើសនិស្សិតឱ្យចូលរៀនថ្នាក់ឧត្តមសិក្សា ដោយគេបានរកឃើញករណីលួចកែទិន្នន័យនិស្សិតអាហារូបករណ៍យ៉ាងតិចចំនួន១០នាក់ ដែលត្រូវចូលសិក្សានៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។ ប៉ុន្តែបើតាមកាសែត ***រស្មីកម្ពុជា*** ចេញផ្សាយថ្ងៃទី២៥ មីនា បានឱ្យដឹងថា មិនទាន់មានការចាត់វិធានការណាមួយនៅឡើយទេ។ កាសែតក្នុងស្រុកមួយចំនួនបានចុះផ្សាយនូវការចោទ

ប្រកាន់មួយថា និស្សិតមានឈ្មោះចូលរៀនមិនប្រក្រតីចំនួន១០នាក់ដែលគេរកឃើញ គឺសុទ្ធតែជាកូនអ្នកមាន ហើយពួកគេបានចំណាយលុយ៣០០០ទៅ៥០០០ដុល្លារ ដើម្បីឱ្យក្រុមអ្នកបញ្ចូលទិន្នន័យលួចកែពាក្យសុំអាហាររូបករណ៍ ធ្វើឱ្យនិស្សិតដែលត្រូវជាប់ពិតប្រាកដ មិនអាចទទួលបានអាហារូបករណ៍។ម្យ៉ាងវិញទៀតអ្នកប្រព្រឹត្តទង្វើខាងលើនេះ ជាអ្នកដែលមានបក្សពួកធំ និងមានលក្ខណៈជាប្រព័ន្ធ។ ទាក់ទងនឹងបញ្ហានេះ ***រស្មីកម្ពុជា*** បានដកស្រង់ប្រសាសន៍ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ថាលោកបានដឹង ហើយកំពុងចុះស៊ើបអង្កេតនិងចាត់វិធានការត្រួត ពិនិត្យវាយតម្លៃលើបញ្ហាខាងលើនេះ។